# រឿងទី២៖ ដាវីឌ និងកូលីយ៉ាត

**ខគម្ពីរ៖ ១សាំយូអែល១៧៖៤៥**

ដាវីឌឆ្លើយទៅវិញថា៖ «ឯងកាន់ដាវ កាន់លំពែង និងស្នូ មកវាយអញ រីឯអញវិញ អញមកវាយឯង ក្នុងនាមព្រះអម្ចាស់ នៃពិភពទាំងមូល ជាព្រះនៃពលទ័ពអ៊ីស្រាអែល ដែលឯងបានបំបាក់មុខ។

ដាវីឌគឺជាអ្នកគង្វាលចៀម។ ទោះដាវីឌហាត់នឿងពីការខិតខំធ្វើការជាអ្នកគង្វាលក៏ដោយ ក៏គាត់មិនភ្លេចលេងពិណសសើរតម្កើងព្រះជាម្ចាស់ដែរ។

ក្នុងចំណោមមិត្តភក្តិទាំងអស់ ដាវីឌល្បីថាជាមេដឹកនាំច្រៀងសសើរតម្កើងដែលពូកែលេងពិណជាងគេ។ មួយវិញទៀត ដាវីឌក៏ជាអ្នកអធិស្ឋានដែលស្វាហាប់ជាងគេដែរ។

ដាវីឌ ជឿថាព្រះជាម្ចាស់តែងតែគង់នៅ និងធ្វើការជាមួយគាត់។

ពេលដាវីឌឃ្វាលហ្វូងចៀម តែងតែមានសត្វតោ និងខ្លាឃ្មុំចេញមកដើម្បីចាប់ចៀមស៊ី។

ដាវីឌនៅក្មេងខ្លាំងណាស់ ឱ្យទៅតយុទ្ធជាមួយសត្វតោ និងខ្លាឃ្មុំកាចសាហាវនោះគឺមិនអាចទៅរួចទេ។

ដូច្នេះ ដាវីឌបានអធិស្ឋានទៅព្រះជាម្ចាស់។ ដើម្បីការពារហ្វូងចៀមពីសត្វតោនិងខ្លាឃ្មុំ ដាវីឌបានហាត់រៀនគ្រវីខ្សែដង្ហក់ គប់សត្វទាំងនោះដែលចង់មកចាប់ស៊ី ហ្វូងចៀមរបស់ខ្លួន។

ពេលដាវីឌគ្រវីខ្សែដង្ហក់គប់ទៅលើសត្វតោ និងខ្លាឃ្មុំដែលកំពុងខាំពាំចៀមនិងមាត់ ត្រូវគ្មានខុស ធ្វើឱ្យសត្វទាំងនោះ ឈឺ ក៏ទម្លាក់ចៀមចុះមកវិញ រួចស្រែកយំរត់ទៅបាត់។

មានថ្ងៃមួយ ស្រុកអ៊ីស្រាអែលមានសង្គ្រាមជាមួយពួកជនជាតិភីលីស្ទីន។

ពេលនោះឪពុកបានប្រើដាវីឌឱ្យទៅជួបបងៗដែលនៅសមរភូមិ ហើយក៏បានឮកូលីយ៉ាតកំពុងនិយាយមើលងាយ រាស្ត្ររបស់ព្រះជាម្ចាស់។

ដាវីឌបានសួរទៅជនជាតិអ៊ីស្រាអែលថាហេតុអ្វីបានជាជនជាតិភីលីស្ទីននេះហ៊ាននិយាយមើលងាយដល់ទាហាន របស់ព្រះជាម្ចាស់ដូច្នេះ។

ក្រោយពីស្តាប់ពាក្យរបស់ដាវីឌហើយមានមនុស្សម្នាក់បានយកពាក្យនោះទៅប្រាប់ស្តេចសូល។ ស្តេចសូលបានឱ្យ ដាវីឌចូលទៅក្នុងព្រះរាជវាំង។

ស្តេចសូល បាននិយាយជាមួយដាវីឌ ហើយក៏អនុញ្ញាតឱ្យដាវីឌចេញទៅធ្វើសង្គ្រាម។

ដាវីឌជឿជាក់ថាព្រះជាម្ចាស់ទ្រង់នឹងជួយគាត់អាចយកឈ្នះលើកូលីយ៉ាតនិងជនជាតិភីលីស្ទីនដែលមើលងាយព្រះជាម្ចាស់ជាមិនខាន។

មុនពេលដាវីឌចេញទៅច្បាំងជាមួយកូលីយ៉ាត ដាវីឌបានទៅយកដំបងនិងខ្សែដង្ហក់ដែលខ្លួនតែងប្រើនៅពេលដេញ សត្វតោ និងខ្លាឃ្មុំពេលឃ្វាលចៀម រួមជាមួយនិងដុំថ្មចំនួនប្រាំដុំដាក់ក្នុងថង់។

ពេលឃើញដាវីឌដែលចេញមកច្បាំងជាមួយខ្លួនភ្លាម កូលីយ៉ាតបានសើចចំអកដល់ដាវីឌជាខ្លាំង។

ប៉ុន្តែ ដាវីឌមិនមានការភ័យខ្លាចអ្វីសោះ។





ដាវីឌបានរត់សំដៅទៅរកកូលីយ៉ាតយ៉ាងលឿន ហើយបានគប់ដុំថ្មចំថ្ងាស់កូលីយ៉ាត។
យក្សកូលីយ៉ាត ក៏បានដួលចុះ ក្រោយត្រូវមួយដុំថ្មដែលហោះមកនោះ សន្លប់បាត់មាត់ឈឹង។
ដាវីឌបានចូលទៅឈរជិតកូលីយ៉ាតដោយនៅក្នុងដៃមិនមានដាវ ដាវីឌក៏បានយកដាវកូលីយ៉ាតមកកាត់ផ្តាច់កកូលីយ៉ាតទៅ។
ជនជាតិភីលីស្ទីនដែលបានឃើញហេតុការណ៍នេះ មានការភ័យខ្លាចជាខ្លាំង ក៏រត់បាស់ជើងគ្រប់គ្នា។ នៅថ្ងៃនោះ ជ័យជម្នះដ៏ធំក៏កើតមានលើរាស្ត្រអ៊ីស្រាអែល។
ពេលដាវីឌឃ្វាលចៀមហើយមានសត្វសាហាវៗដូចជាសត្វតោ និងខ្លាឃ្មុំ បានលេចមក ពេលនោះគាត់តែងជឿលើ ព្រះជាម្ចាស់ ហើយពឹងផ្អែកលើទ្រង់ ដែលនាំឱ្យគាត់អាចយកឈ្នះលើសត្រូវបានដោយកម្លាំងដែលមកពីព្រះជាម្ចាស់ ។
ដំបូងឡើយ ដាវីឌបានយកឈ្នះលើសត្វតោ ឬខ្លាឃ្មុំ ប៉ុន្តែ ពេលនេះ  ដាវីឌក៏បានយកឈ្នះលើមេទ័ពកូលីយ៉ាតដែល មានមាឌធំដូចយក្ស ដែលបានមកគំរាមគំហែងរាស្ត្រអ៊ីស្រាអែលនោះ ក្រោយពីនោះ គាត់បានសង្គ្រោះអ៊ីស្រាអែល និងទទួលបានជ័យជម្នះដ៏អស្ចារ្យ។

● សូមសរសេរតាមខគម្ពីរខាងក្រោម រួចទន្ទេញ។ (១សាំយូអែល១៧៖៤៥)

រីឯអញវិញ អញមកវាយឯង ក្នុងនាម ព្រះអម្ចាស់ នៃពិភពទាំងមូល



**សកម្មភាពទី១** តើដាវីឌត្រូវដើរតាមផ្លូវណា ដើម្បីឲ្យដុំថ្មដែលបានបោះទៅនោះ ប៉ះថ្ងាសរបស់កូលីយ៉ាត?



**សកម្មភាពទី២** សូមគិតពីខ្លឹមសារមេរៀនដែលបានរៀននៅថ្ងៃនេះ រួចផាត់ពណ៌រូបភាពខាងក្រោម។

